# នីហ្វៃ អធិស្ឋានសម្រាប់ប្រជាជន

*អ្នកអាចអានដំណើររឿងនេះនៅក្នុង*
*ហេលេមិន ៧:១០–១៧ និង ៨:៧–១០*



នីហ្វៃ គឺជាព្យាការី ។ លោកត្រូវបានដាក់ឈ្មោះតាមនីហ្វៃដែលបានយកផ្ទាំងលង្ហិន ។ លោកបានព្រួយបារម្ភអំពីប្រជាជន ។ ពួកគេឈប់ធ្វើតាមព្រះ ។



នីហ្វៃបានទៅសួនច្បាររបស់លោក ។ លោកបានឡើងទៅលើប៉មមួយនៅក្នុងសួនច្បារ ហើយបានអធិស្ឋានទៅកាន់ព្រះនៅទីនោះ ។ លោកបានអធិស្ឋានសម្រាប់ប្រជាជននេះ ។



មនុស្សមួយចំនួនបានកត់សម្គាល់ឃើញ នីហ្វៃនៅលើប៉ម ។ ពួកគេឈប់ដើម្បីស្តាប់ ហើយប្រមូលអ្នកឯទៀតឲ្យស្តាប់ដែរ ។ នៅពេលនីហ្វៃបញ្ចប់ការអធិស្ឋាន លោកបានកត់សម្គាល់ឃើញថាពួកគេកំពុងមើល ហើយបានចាប់ផ្តើមបង្រៀនដល់ពួកគេ ។



នីហ្វៃបានសុំឲ្យប្រជាជនប្រែចិត្ត ។ ពួកគេមួយចំនួនមិនចូលចិត្តអ្វី ដែលនីហ្វៃបានបង្រៀននោះទេ ។ តែមនុស្សជាច្រើនផ្សេងទៀតបានស្តាប់តាម ! ពួកគេបានជ្រើសរើសប្រែចិត្ត ហើយផ្លាស់ប្តូរទម្លាប់របស់ពួកគេ ។ ●